អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១១ ខែ វិច្ឆិកា ឆ្នាំ ២០១៥

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះតុលាការកំពូល
# កំណត់កាលបរិច្ឆេទសវនាការលើសំណុំរឿង ០០២/០១

អង្គជំនុំជម្រះតុលាការកំពូលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានកំណត់កាលបរិច្ឆេទសវនាការលើបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។ សវនាការនេះនឹងចាប់ផ្តើមពីម៉ោង៩:00 ព្រឹក ដល់ម៉ោង ១១:៣០ នាទី និងនៅពេលរសៀល ចាប់ពីម៉ោង ១:៣០នាទី ដល់ ម៉ោង ៤:00 រសៀល ចាប់ពីថ្ងៃទី ១៧ ១៨ និង ១៩ ខែ វិច្ឆិកា ឆ្នាំ ២០១៥ ខាងមុខនេះ។ របៀបវារៈលម្អិតអំពីដំណើការសវនាការរយៈពេលបីថ្ងៃអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់អ.វ.ត.ក http://www.eccc.gov.kh/en/document/court/annex-final-timetable-hearing ។

សវនាការនេះ ពាក់ព័ន្ធទៅនឹងបណ្តឹងសាទុក្ខរបស់សហព្រះរាជអាជ្ញា នួន ជា និង ខៀវ សំផន ប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងសំណុំរឿង ០០២/០១ ដែលបានចេញនៅថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤។ បណ្តឹងសាទុក្ខនេះ គឺមានទំហំធំធេង និងស្មុគស្មាញ ប្រសិនបើប្រៀបធៀបនឹងកិច្ចដំណើរការនីតិវិធីដទៃទៀតដែលពាក់ព័ន្ធទៅនឹងអំពើឃោរឃៅដ៏ធ្ងន់ធ្ងរដែលរងការចោទប្រកាន់នោះ។ សារណា ប្រតិចារិកសវនាការ និងភស្តុតាងជាឯកសារនៃសំណុំរឿងដែលជាមូលដ្ឋានសម្រាប់កិច្ចដំណើរការនីតិវិធីមានចំនួនរាប់រយពាន់ទំព័រ។ បន្ថែមលើនេះទៀត ម្ចាស់បណ្តឹងសាទុក្ខ បានលើកឡើងនូវទឡ្ហីករណ៍ជាង ៣៧០ នៅក្នុងបណ្តឹងសាទុក្ខ ដោយរួមបញ្ចូលទាំងបញ្ហាដែលពុំបានកើតឡើងនៅក្នុងសាលក្រមខ្លួនឯងផងដែរ ប៉ុន្តែបានកើតឡើងនៅក្នុងពេលកិច្ចដំណើរការនីតិវិធីជំនុំជម្រះ។ នួន ជា និង ខៀវ សំផន បានធ្វើបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង ដោយម្នាក់ៗបានលើកទឡ្ហីករណ៍បណ្តឹងសាទុក្ខចំនួន២២៣ និង១៤៨ រៀងៗខ្លួន។ បន្ថែមលើសពីនេះ សហព្រះរាជអាជ្ញាវិញ បានដាក់បណ្តឹងសាទុក្ខដោយកម្រិតត្រឹមតែស្វែងរក

ដំណោះស្រាយដែលប្រកាសដោយអង្គជំនុំជម្រះតុលាការកំពូលទាក់ទងនឹងភាពអាចអនុវត្តបាននូវទម្រង់ពង្រីកបន្ថែមនៃសហឧក្រិដ្ឋកម្មរួម ដែលហៅថា "សហឧក្រិដ្ឋកម្មរួមទម្រង់ទី III" (JCE) នៅចំពោះមុខ អ.វ.ត.ក។ ខុសពីតុលាការព្រហ្មទណ្ឌអន្តរជាតិ និងស្តង់ដារអន្តរជាតិដទៃទៀត ដោយយោងតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក បញ្ហាទាំងនេះពុំត្រូវបានអនុញ្ញាតឱ្យធ្វើបណ្តឹងសាទុក្ខដាច់ដោយឡែកពីគ្នាឡើយ ប៉ុន្តែត្រូវបានអនុញ្ញាតឱ្យលើកឡើងតែនៅពេលបណ្តឹងសាទុក្ខប្រឆាំងនឹងសាលក្រមប៉ុណ្ណោះ។

សវនាការនឹងបើកទូលាយសម្រាប់សាធារណៈជន និងតំណាងសារព័ត៌មាន ហើយកន្លែងអង្គុយនៅក្នុងសាលសវនាការនឹងត្រូវចែកជូនដោយគោរពតាមគោលការណ៍ អ្នកមកមុន បានមុន លើកលែងតែកន្លែងអង្គុយដែលត្រូវបានរក្សាទុកសម្រាប់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងនេះ។

ក្នុងករណីដែលពុំទាន់មានការសម្រេចលើបញ្ហានៃបណ្តឹងសាទុក្ខនេះទេ ជនជាប់ចោទនៅតែត្រូវបានសន្មតថាគ្មានទោស។ អង្គជំនុំជម្រះតុលាការកំពូលរំពឹងទុកថា សាធារណៈជន មន្ត្រីរាជការ ប្រព័ន្ធផ្សព្វផ្សាយសារព័ត៌មានគោរពគោលការណ៍សច្ចធារណ៍នៃនិរទោសនេះនៅក្នុងសេចក្តីថ្លែងការណ៍ណាមួយដែលខ្លួនមានបំណងធ្វើឡើងស្តីអំពីរឿងក្តីនេះ និងជនជាប់ចោទ។

<u>តំណាងប្រព័ន្ធផ្សព្វផ្សាយដែលមានបំណងចូលរួមក្នុងសវនាការលើបណ្តឹងសាទុក្ខនេះ តម្រូវឱ្យមានប័ណ្ណសម្រាប់អ្នកសារព័ត៌មាន និងត្រូវចុះឈ្មោះជាមុន</u>។ សូមអនុវត្តតាមលក្ខខណ្ឌដូចខាងក្រោមដើម្បីស្នើសុំប័ណ្ណព័ត៌មាន៖

ក) អ្នកសារព័ត៌មានដែលមិនទាន់មានប័ណ្ណព័ត៌មានដែលចេញដោយ អ.វ.ត.ក ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណសារព័ត៌មានដោយ<u>មានចុះហត្ថលេខា</u> ភ្ជាប់រូបថតទម្រង់ jpg មួយសន្លឹក និងច្បាប់ចម្លងលិខិតឆ្លងដែនមួយច្បាប់ ផ្ញើមកជាមួយសំណើសុំចុះឈ្មោះដើម្បីចូលរួមតាមដានសវនាការលើបណ្តឹងសាទុក្ខ តាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh។

ខ) អ្នកសារព័ត៌មានដែលមានប័ណ្ណមានសុពលភាពជាផ្លូវការរបស់ អ.វ.ត.ក ត្រូវចុះឈ្មោះដើម្បីចូលរួមតាមដានសវនាការបណ្តឹងសាទុក្ខនៅផ្នែកកិច្ចការសាធារណៈ តាមរយៈការផ្ញើសារអេឡិចត្រូនិកទៅកាន់ pas@eccc.gov.kh ។

គ) អ្នកសារព័ត៌មានដែលមានប័ណ្ណព័ត៌មានជាផ្លូវការរបស់ អ.វ.ត.ក ប៉ុន្តែផុតកំណត់ ត្រូវបំពេញទម្រង់បែបបទសុំប័ណ្ណព័ត៌មានសារជាថ្មី ដោយ<u>មានចុះហត្ថលេខា</u>ផ្ញើមកជាមួយនឹងសំណើសុំចុះឈ្មោះដើម្បីចូលរួមតាមដានសវនាការបណ្តឹងសាទុក្ខតាមរយៈសារអេឡិចត្រូនិក pas@eccc.gov.kh ។

សូមកុំភ្លេចបញ្ជាក់លេខប័ណ្ណចាស់ដែលផុតកំណត់ផង!

ទម្រង់បែបបទសម្រាប់សុំប័ណ្ណព័ត៌មាន អាចទាញយកបានពីគេហទំព័ររបស់ អ.វ.ត.ក: http://www.eccc.gov.kh/sites/default/files/ECCC_Accreditation_Media_Application_Form-2014.doc

ថ្ងៃផុតកំណត់ឈប់ទទួលការចុះឈ្មោះរបស់អ្នកសារព័ត៌មាន និងសំណើសុំប័ណ្ណព័ត៌មាន៖ ថ្ងៃច័ន្ទ ទី១៦ ខែ វិច្ឆិកា ឆ្នាំ ២០១៥ វេលាម៉ោង ១២:០០ ថ្ងៃត្រង់។

សំណុំរឿង០០២/០១ គឺជាការជំនុំជម្រះលើកទីមួយនៃការជំនុំជម្រះយ៉ាងតិចពីរប្រឆាំងនឹង ខៀវ សំផន ជាប្រមុខរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យ និង នួន ជា អតីតអនុលេខាបក្សកុម្មុយនីស្តកម្ពុជា។ បទចោទនៅក្នុង សំណុំរឿង ០០២/០១ គឺផ្តោតលើបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ដែលរងការចោទប្រកាន់ក្នុងអំឡុងពេលជម្លៀសប្រជាជននៅក្នុងទីក្រុងភ្នំពេញក្នុងខែ មេសា ឆ្នាំ ១៩៧៥ និងការផ្លាស់ទីដោយបង្ខំបន្តបន្ទាប់ពីតំបន់ដទៃទៀត រួមទាំងការកាប់សម្លាប់ដែលរងការចោទប្រកាន់នៅទួលពោធិ៍ជ្រៃ ក្នុងខេត្តពោធិ៍សាត់។ កាលពីថ្ងៃទី ៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូងរកឃើញថា ជនជាប់ចោទមានពិរុទ្ធភាពពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ និងបានសម្រេចប្រកាសទោសដាក់ពន្ធនាគារជនជាប់ចោទទាំងពីរអស់មួយជីវិត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឌីម សុវណ្ណារុំ**
ប្រធានផ្នែកកិច្ចការសាធារណៈនៃសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥ (0)១២ ៥១៨៤៨៥
ទូរស័ព្ទ: + (៨៥៥) ២៣ ២១៩ ៨១៤
សារអេឡិកត្រូនិក:dim.sovannarom@eccc.gov.kh

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ: +៨៥៥(0)១២ ៤៨៨ ០២៣
ទូរស័ព្ទ: +៨៥៥(0)២៣ ២១៩ ៨៤១ លេខបន្ត: ៦១៦៩
សារអេឡិចត្រូនិក: olsenl@un.org